ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៨១ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០០១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងមុខតំណែងឥស្សរជនជារដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៤៧ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរ និងតែងតាំងមុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- បានឃើញសេចក្តីសម្រេចលេខ ៧៤ សសរ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**ប្រការ១.-**

កំណត់ និងប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំដៅធានាការដឹកនាំ និងអនុវត្តកិច្ចការរបស់ក្រសួង ដូចខាងក្រោម÷

១- **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** ទទួលដឹកនាំការងាររួមរបស់ក្រសួង ដឹកនាំរៀបចំ និងអនុវត្តរាល់គោលនយោបាយ យុទ្ធសាស្ត្រ និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ដឹកនាំតម្រង់ទិសជាយុទ្ធសាស្ត្រលើកិច្ចការគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ផែនការ និងថវិការបស់ក្រសួង។

២- ឯកឧត្តម **តឹកវ៉េត សំរេច រដ្ឋលេខាធិការប្រចាំការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷
- សម្របសម្រួល និងដឹកនាំបេសកកម្មប្រចាំថ្ងៃរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលកំណត់ក្នុងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- ដឹកនាំការងារជាយុទ្ធសាស្ត្រ ផែនការ ថវិកា គោលនយោបាយ និងការងារអធិការកិច្ច
- ឧស្សាហកម្មអចលនទ្រព្យ
- ដឹកនាំការងារនៃការផ្សារភ្ជាប់រវាងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយនឹងសន្តិសុខនយោបាយ សេដ្ឋកិច្ច និងសង្គម
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៣- ឯកឧត្តម **ឆាន់ សាផាន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷
- រដ្ឋបាល និងហិរញ្ញវត្ថុ
- កិច្ចការលំនៅឋាន
- ច្រកចេញ-ចូលតែមួយ
- កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

- ពិនិត្យ និងចុះហត្ថលេខាលើសំណើសុំអញ្ជើញតំណាងក្រសួង ស្ថាប័នរដ្ឋ និងវិស័យឯកជន ចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីនានានៅក្នុងប្រទេស
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៤- ឯកឧត្តម **ឆេព ឆន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងតាមដានសម្របសម្រួលកិច្ចការវិវាទដីធ្លី
- កិច្ចការវិនិយោគ និងជាតំណាងក្រសួងប្រចាំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៥- ឯកឧត្តម **សរ សុវណ្ណា រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ភូមិសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មានសុរិយោដី
- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- ចុះបញ្ជីដីរដ្ឋ និងការងារចុះបញ្ជីដីជាប្រព័ន្ធ
- កសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ (NSDI)
- កិច្ចការព្រំដែន
- មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៦- ឯកឧត្តម **ម៉ែន សុផល រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- រៀបចំដែនដី និងនគរូបនីយកម្ម
- គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម
- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា (គ.អ.ឆ.ក)
- ជាតំណាង គ.អ.ឆ.ក ក្នុងការពិនិត្យនិងវាយតម្លៃរាល់សំណើវិនិយោគនិងអភិវឌ្ឍន៍ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈស្ថាបត្យករកម្ពុជា
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅតំបន់ឆ្នេរសមុទ្រកម្ពុជា។

៧- ឯកឧត្តម **ថេង ចំន្ទសទ្វារ រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អភិវឌ្ឍ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- បណ្តុះបណ្តាលវិជ្ជាជីវៈ
- កសាងផែនការសកម្មភាព និងបូកសរុបវឌ្ឍនភាពការងាររបស់ក្រសួង
- ទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ។

៨- លោកជំទាវ **ទេព ម្ញ៉ាមីន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- គម្រោងកែលម្អជីវភាព និងសុវត្ថិភាពស្បៀង
- គាំទ្រសកម្មភាពសង្គម វប្បធម៌ និងការលើកកម្ពស់សមភាពយេនឌ័រ
- កិច្ចការលំនៅឋាន
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

៩- ឯកឧត្តម **លាង មុនីរិទ្ធ រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- សិក្សាគម្រោងប្លង់ និងការងារត្រួតពិនិត្យគុណភាពសម្ភារសំណង់
- ស្រាវជ្រាវបច្ចេកទេសសំណង់
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់
- ការងារពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំក្រុងក្នុងខេត្តសៀមរាប
- តាមដាន និងស្រង់ព័ត៌មានពីគេហទំព័រផ្លូវការ និងប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គមរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- ដឹកនាំការងារផ្សព្វផ្សាយតាមគេហទំព័រផ្លូវការ និងប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គមរបស់ក្រសួង
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

១០- ឯកឧត្តម **ឡៅ និពូសីហា រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- សំណង់ និងការងារត្រួតពិនិត្យគុណភាព សុវត្ថិភាព និងការប្រើប្រាស់សំណង់
- មន្ទីរពិសោធន៍ជាតិសំណង់
- បូកសរុបទិន្នន័យសំណង់
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។

១១- ឯកឧត្តម **ឡោ ជាទុន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- អភិរក្សសុរិយោដី និងការងារបច្ចេកទេសសុរិយោដី
- ចុះបញ្ជីដីរដ្ឋ និងការងារចុះបញ្ជីដីជាប្រព័ន្ធ
- គ្រប់គ្រង និងរៀបចំដីធ្លី
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១២- ឯកឧត្តម **សុខ សូភាន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- បណ្តុះបណ្តាលវិជ្ជាជីវៈ
- ឧស្សាហកម្មអចលនទ្រព្យ
- កិច្ចការលំនៅឋាន
- ទំនាក់ទំនងជាមួយរដ្ឋសភា និងព្រឹទ្ធសភា
- កិច្ចសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

១៣- ឯកឧត្តម **លី រស្មី រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- រៀបចំដែនដី និងនគរូបនីយកម្ម
- គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- គណៈស្ថាបត្យករកម្ពុជា

- មន្ទីរពិសោធន៍ជាតិសំណង់
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១៤- ឯកឧត្តម **ផារ៉ា មង្គល រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ពិនិត្យសំណើសុំការអនុញ្ញាតសាងសង់ គោលការណ៍សាងសង់ និងការអភិវឌ្ឍដី
- កិច្ចការសម្បទានដីសង្គមកិច្ចជូនគ្រួសារកងទ័ព និងនគរបាលជាតិតាមបណ្តោយព្រំដែន
- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- កិច្ចការលំនៅឋាន
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ធំ។

១៥- លោកជំទាវ **តឹក លក្ខិណា រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ស្រាវជ្រាវ និងបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម
- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម
- គណៈស្ថាបត្យករកម្ពុជា
- គាំទ្រសកម្មភាពសង្គម វប្បធម៌ និងការលើកកម្ពស់សមភាពយេនឌ័រ
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១៦- ឯកឧត្តម **ហេង ឡាលីន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- អភិវឌ្ឍអចលនទ្រព្យ
- ហិរញ្ញប្បទានលើវិស័យអចលនទ្រព្យ
- ការងារសម្បទានដីសង្គមកិច្ច
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ។

១៧- ឯកឧត្តម **ឈឿន ម៉ុណ្ណារ័ត្ន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- សម្របសម្រួលការងាររួមជាមួយឯកឧត្តម **ឆាន់ សាផាន** លើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ,

កិច្ចការលំនៅឋាន, កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

- រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង
- បុគ្គលិក និងគ្រប់គ្រង កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

១៨- ឯកឧត្តម **រស់ សាលីន រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- គម្រោងអភិវឌ្ឍ និងស្ដារវិស័យអចលនទ្រព្យ
- រៀបចំផែនការអភិវឌ្ឍន៍ដីធ្លី ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច
- ផែនការតម្រង់ទិសការអភិវឌ្ឍអចលនទ្រព្យ ដើម្បីបម្រើមុខងារសេដ្ឋកិច្ច
- ផែនការតម្រង់ទិសអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សានិងរៀបចំផែនការនិរន្តរភាពសេដ្ឋកិច្ចនិងសង្គម នៃសហគមន៍ក្នុងតំបន់សម្បទានដីសង្គមកិច្ច
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

១៩- លោកជំទាវ **សេង សុមេត្តា រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- សេវាសាធារណៈក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ប្រមូលផ្ដុំទិន្នន័យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បច្ចេកវិទ្យាព័ត៌មានសុរិយោដី
- ការងារប្រឆាំងការសម្អាតប្រាក់
- កិច្ចការហិរញ្ញវត្ថុ និងផែនការថវិការបស់ក្រសួង
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២០- ឯកឧត្តម **សូ ខនឫទ្ធីគុណា រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ចុះបញ្ជីដីរដ្ឋ
- រៀបចំដីធ្លីសម្រាប់មុខងារកសិកម្ម

- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។

២១- ឯកឧត្តម **សៅ សុភាព រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្សារភ្ជាប់ការអភិវឌ្ឍសេដ្ឋកិច្ច (ការងាររបៀងសេដ្ឋកិច្ច)
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅតំបន់ឆ្នេរសមុទ្រកម្ពុជា។

២២- ឯកឧត្តម **ស្រ៊ុន ដារិទ្ធិ រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី និងនគរូបនីយកម្ម
- រៀបចំដីធ្លីសម្រាប់មុខងារកសិ-ឧស្សាហកម្ម
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅតំបន់ឆ្នេរសមុទ្រកម្ពុជា។

២៣- ឯកឧត្តម **សុខ គាង រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី និងនគរូបនីយកម្ម
- កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- ពិនិត្យ និងសម្រេចក្នុងនាមរដ្ឋមន្ត្រី លើការចាត់បញ្ជូនមន្ត្រីចូលរួមកិច្ចប្រជុំនិងវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ចាប់ពីមន្ត្រីធម្មតា រហូតដល់មន្ត្រីថ្នាក់អគ្គនាយករង
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន។

២៤- ឯកឧត្តម **រ័ត្ន ទិរៈ រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷

- សម្បទានដីសង្គមកិច្ច
- រៀបចំដីធ្លីសម្រាប់មុខងារកសិកម្ម និងសន្តិសុខស្បៀង

- កិច្ចប្រជុំសម្របសម្រួលរវាងក្រសួងជាមួយគណៈស្ថាបត្យករកម្ពុជា, សមាគមអ្នកអភិវឌ្ឍលំនៅឋាននៅកម្ពុជា, សមាគមអ្នកសាងសង់កម្ពុជា និងសមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនទ្រព្យកម្ពុជា
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ផែនការតម្រង់ទិសការរៀបចំដែនដី ផ្សារភ្ជាប់ប៉ូលសេដ្ឋកិច្ច នៅខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

២៥- ឯកឧត្តម **យស់ ឆោមណារ៉ាឌី រដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ÷
- នគរូបនីយកម្ម ការរៀបចំផែនការប្រើប្រាស់ដី និងការរៀបចំក្រុងឱ្យបានគ្រប់ទីប្រជុំជន
- គណៈស្ថាបត្យករកម្ពុជា
- គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ចូលរួមដឹកនាំការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២៦- លោកជំទាវ **ឆិត្យ ច័ន្ទតារីន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷
- គាំទ្រសកម្មភាពសង្គម វប្បធម៌ និងការលើកកម្ពស់សមភាពយេនឌ័រ
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តសៀមរាប។

២៧- ឯកឧត្តម **ឌុច ធនធីតូ អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷
- នគរូបនីយកម្ម
- រៀបចំដែនដី និងគម្រោងសម្បទានដីសង្គមកិច្ច
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តស្វាយរៀង។

២៨- ឯកឧត្តម **ឆា ច័ន្ទលីដា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷
- ស្រាវជ្រាវបច្ចេកទេសសំណង់

- សិក្សាគម្រោងប្លង់គ្រឿងផ្គុំ
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

២៩- ឯកឧត្តម **អ៊ឹម ចំរុង អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- គុណភាពសំណង់
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តក្រចេះ។

៣០- ឯកឧត្តម **កើត សារ៉េត អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- ស្រាវជ្រាវបច្ចេកទេសសំណង់
- នគរូបនីយកម្ម
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសំណង់
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកោះកុង។

៣១- ឯកឧត្តម **សៀក វណ្ណា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- រៀបចំដែនដី និងអភិរក្សសុរិយោដី
- អភិវឌ្ឍនិងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តតាកែវ។

៣២- ឯកឧត្តម **មាន ច័ន្ទវ៉ាន់នី អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- នគរូបនីយកម្ម និងគណៈស្ថាបត្យករកម្ពុជា
- កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកណ្ដាល។

៣៣-ឯកឧត្តម **សេង ថានី អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- លំនៅឋាន និងនគរូបនីយកម្ម
- កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ។

៣៤- ឯកឧត្តម **ខិម សំអ៊ែល អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- រដ្ឋបាល និងហិរញ្ញវត្ថុ
- កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្លូកសរុបវឌ្ឍនភាពការងាររបស់ក្រសួង ការកសាងផែនការ និងតាមដានការអនុវត្តសេចក្ដីសម្រេចរបស់ក្រសួង
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។

៣៥- ឯកឧត្តម **ខ្លូត រតនា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- សិក្សាគម្រោងប្លង់ស្ថាបត្យកម្ម
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ។

៣៦- ឯកឧត្តម **លី វណ្ណសុត្រា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- សិក្សាគម្រោងប្លង់ស្ថាបត្យកម្ម
- គណៈស្ថាបត្យករកម្ពុជា
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង។

៣៧- ឯកឧត្តម **ហ៊ុន ម៉ុនថាន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- កម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី
- គណៈស្ថាបត្យករកម្ពុជា
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តរតនគីរី។

៣៨- លោកជំទាវ **សេរី សុរិយា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- សិក្សាគម្រោងប្លង់ស្ថាបត្យកម្ម
- ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី និងនគរូបនីយកម្ម
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តត្បូងឃ្មុំ។

៣៩- ឯកឧត្តម **ហាន់ឡ សុតសំនារ អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- សិក្សាគម្រោងប្លង់ស្ថាបត្យកម្ម
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈស្ថាបត្យករកម្ពុជា
- គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ទំនាក់ទំនងជាមួយអាជ្ញាធរជាតិអប្សរា, អាជ្ញាធរជាតិព្រះវិហារ, អាជ្ញាធរជាតិសំបូរព្រៃគុក

- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

៤០- ឯកឧត្តម **ម៉ែន រ័ត្ន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- គ្រប់គ្រងដីធ្លី និងអធិការកិច្ច
- លំនៅឋានបណ្តោះអាសន្ន
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ។

៤១- ឯកឧត្តម **ឡឹម សុគី អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- វាយតម្លៃអចលនទ្រព្យ
- នគរូបនីយកម្ម
- សេវាសាធារណៈក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អភិវឌ្ឍ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- កិច្ចការអាស៊ាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ទំនាក់ទំនងជាមួយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តព្រៃវែង។

៤២- ឯកឧត្តម **លីច សុផាណ្ណារ៉េន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- អភិវឌ្ឍសេដ្ឋកិច្ច កិច្ចការវិនិយោគ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- ប្លូកសុរបវឌ្ឍនភាពការងាររបស់ក្រសួង
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។

៤៣- លោកជំទាវ **តឹម វុនស៊ីណារតន៍ អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- គាំទ្រសកម្មភាពសង្គម វប្បធម៌ និងការលើកកម្ពស់សមភាពយេនឌ័រ
- តាមដាន និងស្រង់ព័ត៌មានពីគេហទំព័រផ្លូវការ និងប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គមរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- រៀបចំខ្លឹមសារព័ត៌មានក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ដឹកនាំការងារផ្សព្វផ្សាយតាមគេហទំព័រផ្លូវការ និងប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គមរបស់ក្រសួង
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកណ្តាល។

៤៤- ឯកឧត្តម **ហ៊ិន កុសល អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- អភិវឌ្ឍ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សមាគម អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដទៃទៀត ពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- វប្បធម៌ និងព័ត៌មាន
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកំពត។

៤៥- ឯកឧត្តម **លី ដាទុង អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង
- អភិវឌ្ឍ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- កិច្ចការលំនៅឋាន
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។

៤៦- ឯកឧត្តម **ស្រ៊ុន តារា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- សមាគម អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដទៃទៀត ពាក់ព័ន្ធនឹងសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តប៉ៃលិន។

៤៧- ឯកឧត្តម **ម៉ៅ វិបុល អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- រៀបចំដីធ្លីផ្សារភ្ជាប់នឹងតំបន់វប្បធម៌ និងទេសចរណ៍
- ជាជនបង្គោលសម្រាប់ការងារកិច្ចសហប្រតិបត្តិការជាមួយភាគីអូស្ត្រាលី
- រៀបចំសេចក្តីសង្ខេបគោលនយោបាយ
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកំពង់ចាម។

៤៨- ឯកឧត្តម **គិត ច័ន្ទត្រីស្នា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- ទិន្នន័យព័ត៌មានក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីជួយពន្លឿនការផ្តល់សេវាសាធារណៈ
- ជាជនបង្គោលសម្រាប់ការងារកិច្ចសហប្រតិបត្តិការជាមួយភាគីជប៉ុន
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង។

៤៩- ឯកឧត្តម **សេន ណាស៊ី អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ លើការងារ÷

- រៀបចំដីធ្លីសម្រាប់មុខងារកសិកម្ម

- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី។

៥០- ឯកឧត្តម **សុ សិទ្ធា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកែប។

៥១- ឯកឧត្តម **ខៀវ ម៉ូរិន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- ដឹកនាំ និងសម្របសម្រួលការងាររៀបចំផែនការអភិវឌ្ឍន៍ភូមិ ឃុំ
- ដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។

៥២- ឯកឧត្តម **ផេង ឡេណា អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារ÷

- ជានាយកខុទ្ទកាល័យ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៥៣- លោកជំទាវ **ផល្លី គិមាន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារជានាយិការងខុទ្ទកាល័យ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដែលកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

៥៤- ឯកឧត្តម **ឡោះ ម៉ាន អនុរដ្ឋលេខាធិការ** ទទួលភារកិច្ចជួយរដ្ឋមន្ត្រី និងរដ្ឋលេខាធិការលើការងារដឹកនាំជាយុទ្ធសាស្ត្រលើការងាររៀបចំផែនការការងារ និងផែនការលទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាព ពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង។

**ប្រការ២.-**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មានភារកិច្ចអនុវត្តការងារផ្សេងទៀត ដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៣.-**

រាល់សេចក្តីសម្រេច និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ គ្រប់អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យ**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤ «**ដើម្បីអនុវត្ត**»
- ឯកសារ កាលប្បវត្តិ